**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ......០៩...សសរ

# សេចក្តីសម្រេច

## ស្តីពី

## «ឯកសារណែនាំសំរាប់ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចំរុះ»

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ខែកក្កដាឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៤៧អនក្រ. បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យលេខ ២៧ អនក្រ. បក ចុះថ្ងៃទី១៤ ខែមិនា ឆ្នាំ២០០៦ ស្តីពីការកែសំរួលមាត្រា១ នៃអនុក្រឹត្យលេខ១៤៧ អនក្រ. បក
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សំរេច

**ប្រការ ១ :-**

កំណត់ «ឯកសារណែនាំ » ដូចជូនភ្ជាប់មកជាមួយនេះ សំរាប់ណែនាំដល់ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចំរុះទាំងអស់ ។

**ប្រការ ២ :-**

ប្រធាន ឬសហប្រធាននៃក្រុមការងារបច្ចេកទេសចំរុះនីមួយៗត្រូវស្ម័យវាយតំលៃអំពីដំណើរការកន្លងមករបស់ក្រុមការងារបច្ចេកទេសចំរុះ ដើម្បីលើកវិធានការកែសំរួលមួយចំនួនជាយថាហេតុ ក្នុងស្មារតីធានាឱ្យមានភាពរលូនជាមួយនឹង « ឯកសារណែនាំ » នេះ ដោយត្រូវពិភាក្សាជាមួយសមាជិករបស់ក្រុមការងារពិសេស ជាមួយដៃគូអភិវឌ្ឍន៍ តាមរយៈប្រធានសំរបសំរួលរបស់ដៃគូអភិវឌ្ឍន៍ ។

**ប្រការ ៣ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងក្រុមការងារបច្ចេកទេសចំរុះទាំងអស់ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
- -ដូចប្រការ៣
- -ឯកសារ-កាលប្បវត្តិ